# កិច្ចសន្យាសេវាកម្ម

**រវាង**

**មជ្ឈមណ្ឌលផ្តល់សេវាកម្មធារាសាស្ត្រ**

ការិយាល័យ : ទីរួមខេត្តកំពង់ធំ

តំណាងដោយ លោក **អង់ឆាន់ ជីលីញ** - អ្នកសម្របសម្រួលគម្រោង ASIrri ដែលបន្ទាប់ទៅនេះហៅថា **ភាគី "ក"** ។

**និង**

**សហគមន៍កសិករប្រើប្រាស់ទឹកទំនប់ការពារទឹកប្រៃព្រែនប់**

ការិយាល័យ : ផ្លូវជាតិលេខ៤ ភូមិបឹងវែង ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

ទូរស័ព្ទលេខ: 012 490 295

តំណាងដោយ លោក **យឹម ឈិយ** - ប្រធានគណៈកម្មាធិការកណ្តាលសហគមន៍ដែលបន្ទាប់ទៅនេះហៅថា **ភាគី "ខ"** ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម :**

## ប្រការ ១: គោលបំណងនៃកិច្ចសន្យាសេវាកម្ម

គោលបំណងនៃកិច្ចសន្យាសេវាកម្មនេះគឺ ដើម្បីផ្តល់នូវសេវាកម្មដូចខាងក្រោមដល់**ភាគី "ខ"** :

- ការបណ្តុះបណ្តាលបេក្ខជនអ្នកតំណាងសហគមន៍អាណត្តិទី ៤ ឆ្នាំ ២០០៩ (ដូចមានលំអិតនៅក្នុងរបៀបវារៈភ្ជាប់)
- ការបណ្តុះបណ្តាលគណៈកម្មការរៀបចំការបោះឆ្នោតសហគមន៍ (គ.ប.ប គ.ប.ភ និង អ្នកសង្កេតការណ៍) អាណត្តិទី ៤ ឆ្នាំ ២០០៩ (ដូចមានលំអិតនៅក្នុងរបៀបវារៈភ្ជាប់)

## ប្រការ ២: ការសន្យារបស់អ្នកផ្តល់សេវាកម្ម

**ភាគី "ក"** នឹងបញ្ជូនអ្នកជំនាញមួយរូប (លោក **តាំង សុជាត**) ឱ្យជួយគាំទ្រដល់ **ភាគី "ខ"** ដើម្បីសម្រេចបាននូវគោលបំណងដូចដែលមានបញ្ជាក់ក្នុងប្រការ ១។

**ភាគី "ក"** នឹងសន្យាផ្តល់នូវ សេវាកម្មដូចដែលបានកំណត់នៅក្នុងគោលបំណងខាងលើដោយគោរពទៅតាមកម្មវិធីបេសកកមខាងក្រោម និងសម្របសម្រួលការងារឱ្យបានល្អ។ ការគោរពតាមរយៈពេលកំណត់សម្រាប់លទ្ធផលរំពឹងទុកត្រូវតែអនុវត្តដោយខានមិនបាន។

| កាលបរិច្ឆេទ | | សកម្មភាព | អ្នកចូលរួម | អ្នកសម្របសម្រួល |
|---|---|---|---|---|
| ២៨-០៩-០៩ | ព្រឹក | ធ្វើដំណើរពីភ្នំពេញទៅព្រៃនប់ | | |
| | រសៀល | កាបណ្តុះបណ្តាលបេក្ខជនអ្នកតំណាងសហគមន៍អាណត្តិទី ៤ ឆ្នាំ ២០០៩ (ដូចមានលំអិតនៅក្នុងរបៀបវារៈ) | បេក្ខជនអ្នកតំណាងសហគមន៍<br>- បេក្ខជនប្រធានប៉ុលខ្មែរចំនួន ២០រូប<br>- បេក្ខជនតំណាងភូមិចំនួន ៧៥រូប<br>- នាយកសហគមន៍១រូប និង ភ្នាក់ងារ ៤រូបជាអ្នកសង្កេតការណ៍ | អ្នកជំនាញ ១រូប |
| ២៩-០៩-០៩ | ព្រឹក | កាបណ្តុះបណ្តាលគណៈកម្មការរៀបចំការបោះឆ្នោតសហគមន៍ (គ.ប.ប គ.ប.ភ និងអ្នកសង្កេតការណ៍) អាណត្តិទី ៤ ឆ្នាំ ២០០៩ (ដូចមានលំអិតនៅក្នុងរបៀបវារៈ) | - គ.ប.ប និងគ.ប.ភ ប៉ុលខ្មែរទី១ ចំនួន ៥០រូប<br>- គ.ប.ប និងគ.ប.ភ ប៉ុលខ្មែរទី៣ ចំនួន ៣៧រូប<br>- គ.ប.ប និងគ.ប.ភ ប៉ុលខ្មែរទី៦ ចំនួន ៩រូប<br>- អ្នកសង្កេតការណ៍ចំនួន ៨រូប<br>សរុបចំនួន ៩២រូប | អ្នកជំនាញ ១រូប |
| | រសៀល | | | |
| ៣០-០៩-០៩ | ព្រឹក | ធ្វើដំណើរពីព្រៃនប់ទៅភ្នំពេញ | | |

## ប្រការ ៣: តម្លៃនៃកិច្ចសន្យាសេវាកម្ម

ដោយយោលទៅលើ គោលនយោបាយរបស់គម្រោងមជ្ឈមណ្ឌលផ្តល់សេវាកម្មធារាសាស្ត្ររាល់ការផ្តល់សេវាកម្មទាំងឡាយ ត្រូវទទួលបាននូវការបង់ថ្លៃសម្រាប់សេវាកម្មតាមអត្រាកំណត់មួយដូចខាងក្រោម (តម្លៃនេះមិនល្មមនឹងចំណាយទាំងអស់ដោយមជ្ឈមណ្ឌលទេ ប៉ុន្តែតម្លៃនេះ គ្រាន់តែជាវិភាគទានមួយដោយ ស.ក.ប.ទ ហើយជាតម្លៃដែលគេគណនាសម្រាប់កម្រិតសមល្មមមួយដើម្បីគាំទ្រដល់និរន្តរភាពនៃកិច្ចដំណើរការរបស់មជ្ឈមណ្ឌល):

| បរិយាយមុខចំណាយ | តម្លៃឯកតា ($) | ចំនួនថ្ងៃ | សរុប ($) |
|---|---|---|---|
| - ថ្លៃសេវាកម្មសម្រាប់ទីប្រឹក្សា/អ្នកជំនាញ | 15 | 2.5 | 37.5 |

| | | | |
|---|---|---|---|
| - ថ្លៃធ្វើដំណើរទៅ និងត្រឡប់មកវិញ | 5 | 2 | 10 |
| - សោហ៊ុយប្រចាំថ្ងៃ និងពេលយប់ | 15 | 2 | 30 |
| **សរុបរួម :** | | | 77.5 |

## ប្រការ ៤: ការបង់ប្រាក់

ការបង់ប្រាក់នឹងត្រូវធ្វើឡើងដោយសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្ទេរប្រាក់ចូលទៅក្នុងគណនីរបស់មជ្ឈមណ្ឌលផ្ទាល់ដូចខាងក្រោម :

ធនាគារ : ................

អាស័យដ្ឋានធនាគារ : ខេត្តកំពង់ធំ

លេខគណនី : ................

ឈ្មោះម្ចាស់គណនី : .................

**ភាគី "ខ"** មិនទទួលខុសត្រូវក្នុងការបង់ពន្ធ និងអាករផ្សេងទៀតទាក់ទងនឹងទឹកប្រាក់ខាងលើនេះទេ។

## ប្រការ ៥: ការដោះស្រាយជម្លោះ

ក្នុងករណីមានជម្លោះ ភាគីទាំងពីរនឹងជួបគ្នា ដើម្បីពិភាក្សារកដំណោះស្រាយសមស្របមួយ ។ ក្នុងករណីដែលពុំមានដំណោះស្រាយ ជម្លោះនេះនឹងបញ្ជូនទៅដោះស្រាយនៅតុលាការកម្ពុជា ។

## ប្រការ ៦: ប្រសិទ្ធិភាពនៃកិច្ចសន្យាសេវាកម្ម

កិច្ចសន្យានេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចេញដំណើរនៃបេសកកម្ម ដែលត្រូវចាប់ផ្តើមនៅថ្ងៃ ទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ។

## ប្រការ ៧: រយៈពេលកំណត់នៃការផ្តល់សេវាកម្ម

របាយការណ៍បញ្ចប់មួយ នឹងត្រូវផ្តល់ឱ្យ **ភាគី "ខ"** មិនយឺតជាងថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ ។

## ប្រការ ៨: ការវាយតម្លៃលើការផ្តល់សេវាកម្ម

នៅចុងបញ្ចប់នៃការផ្តល់សេវាកម្ម ឬ យ៉ាងយូរបំផុតរយៈពេលមួយសប្តាហ៍បន្ទាប់ពីបេសកកម្មត្រូវបានបញ្ចប់ **ភាគី "ខ"** នឹងត្រូវសរសេរនូវការវាយតម្លៃខ្លីមួយលើការផ្តល់សេវាកម្ម ដែលនឹងត្រូវផ្ញើទៅមជ្ឈមណ្ឌលផ្តល់សេវាកម្មធារាសាស្ត្រ ។ ការវាយតម្លៃនេះរួមមានការឆ្លើយទៅនឹងសំណួរនានាដូចខាងក្រោម :

- តើសេវាកម្មដែលបានផ្តល់ជូននេះមានប្រយោជន៍ ឬគ្មាន ? ហេតុអ្វី ?

- តើនៅក្នុងសេវាកម្មដែលបានផ្តល់ឱ្យនេះ ផ្នែកអ្វីខ្លះជាផ្នែកដែលមានប្រយោជន៍ជាងគេ ?
- ប្រសិនបើផ្នែកខ្លះនៃសេវាកម្មដែលបានផ្តល់ឱ្យនោះមិនមានប្រយោជន៍ តើផ្នែកណាខ្លះដែលមិនមានប្រយោជន៍នោះ ? ហេតុអ្វី ?
- តើមានផ្នែកណាខ្លះដែលសេវាកម្មមិនបានអនុវត្ត ? ហេតុអ្វី ?
- តើមានការពេញចិត្តនឹងគុណភាពនៃសេវាកម្មនេះដែរឬទេ ? បើមិនពេញចិត្ត ហេតុអ្វី ?
- តើអ្នកជំនាញមានសមត្ថភាពខ្ពស់គ្រប់គ្រាន់តាមការរំពឹងទុករបស់ ស.ក.ប.ទ/ព្រែនប់ឬទេ? ប្រសិនបើមិនគ្រប់គ្រាន់ ហេតុអ្វី ?
- តើគួរឱ្យមានការតាមដានខ្លះ ឬ ការគាំទ្របន្ថែមខ្លះទៀតចំពោះបេសកកម្មជាក់លាក់លើកនេះដែរឬទេ ?
- តើនៅពេលអនាគតដ៏ខ្លីខាងមុខនេះ ស.ក.ប.ទ/ព្រែនប់គិតទុកថានឹងមានសេវាកម្មផ្សេងទៀតទេ ?
- តើជារួម ស.ក.ប.ទ/ព្រែនប់ពេញចិត្ត ឬមិនពេញចិត្តចំពោះសេវាកម្មដែលបានផ្តល់ឱ្យនេះ បើប្រៀបធៀបទៅនឹងតម្លៃសេវាកម្មដែលត្រូវបង់ ?
- តើ ស.ក.ប.ទ/ព្រែនប់មានការអត្ថាធិប្បាយអ្វីខ្លះទេ ?

ធ្វើនៅ...[illegible]... ថ្ងៃទី២៥.. ខែ...០៩..... ឆ្នាំ២០០៩

**មជ្ឈមណ្ឌលផ្តល់សេវាកម្មតារាសាស្ត្រ** | **ស.ក.ប.ទ / ព្រែនប់**

**អ្នកសម្របសម្រួលគម្រោង** | **ប្រធាន**

ម៉េង_ម៉ុយ